ព្រឹទ្ធសភា

អគ្គលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកក្កដា និងទិសដៅការងារខែសីហា ឆ្នាំ២០១៣

នៅក្នុងខែកក្កដានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្ម ពិសេសការបណ្តុះបណ្តាលធនធានមនុស្ស ការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការកសាងគោលនយោបាយនានា ពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការជាតិ អន្តរជាតិ និងបំពេញការងារសំខាន់ៗមួយចំនួនទៀតដូចខាងក្រោម ៖

**I.លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**

-បានប្រជុំពិភាក្សាការងារជាមួយថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន និងបានជួបពិភាក្សាការងារជាមួយភ្ញៀវអន្តរជាតិ (ជប៉ុន ចិន និងម៉ាឡេស៊ី )ព្រមទាំងបានពិនិត្យសម្រេចលើឯកសារផ្សេងៗ ចំនួន ៣៨៤ច្បាប់ ។

**១.សេវាទ្រទ្រង់មុខងារតំណាង៖**

-រៀបចំបែបបទ និងអមដំណើរថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ចុះទៅតាមណ្តាខេត្ត រាជធានីទូទាំងប្រទេស ចំនួន៣៣៤លើក ដើម្បីសំណេះសំណាល សាកសួរសុខទុក្ខសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ប្រជាពលរដ្ឋ ព្យាបាលជំងឺ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៣១លើក ។

-ទទួលពាក្យបណ្តឹង ចំនួន០១ករណី និងបានធ្វើលិខិតអន្តរាគមន៍ជូនទៅស្ថាប័នមានសមត្ថកិច្ចដោះស្រាយ ។



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

**២.ការងារអន្តរជាតិ៖**

-ទទួលគណៈប្រតិភូធុរៈកិច្ចសមាគមអាស៊ានទទួលបន្ទុកកសិ-ពាណិជ្ជកម្មចិន

-មន្ត្រីអគ្គលេខាធិការដ្ឋានចំនួន០៦រូប ទៅទស្សកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍លើវិស័យព័ត៌មានវិទ្យា នៅរដ្ឋសភាវៀតណាម

-ទំនាក់ទំនងជាមួយរដ្ឋសភាវៀតណាម និងស្ថានទូតប្រ៊ុយណេ អំពីវិស័យបច្ចេកវិទ្យាព័ត៌មាន និងដៃគូរអន្តរជាតិនានា ( India, Brunei, Philippine ឥណ្ឌូនេស៊ី ម៉ាឡេស៊ី រុស្ស៊ី អាល្លឺម៉ង់ ថៃ វៀតណាម អូស្ត្រាលី ស្ថានកុងស៊ុលបែលហ្សិក ស្ថានកុងស៊ុលន័រវ៉េស) ដើម្បីសុំអាហារូបករណ៍ និងទស្សនកិច្ចសិក្សា។

**៣.ទំនាក់ទំនងសាធារណៈ៖**

-ទំនាក់ទំនងជាមួយស្ថានីយ៍ទូរទស្សន៍ជាតិ ទូរទស្សន៍អាស៊ីអាគ្នេយ៍ ដើម្បីផ្សព្វផ្សាយសមិទ្ធផលនានារបស់ព្រឹទ្ធសភា និងសាកលវិទ្យាល័យ CUS, CMTC, CDC, AEU, ECCC, CWF, NiDA, Hong kong Center ដើម្បីសុំអាហារូបករណ៍ និងទស្សនកិច្ចសិក្សា ។

-បដិសណ្ឋារកិច្ចអមដំណើរ សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមគោរពវិញ្ញាណក្ខន្ធសពអ្នកឧកញ៉ាមហាភក្តីសប្បុរិសភោជិបតី **ហ៊ុន នាង** និងសម្តេច នរោត្តម **រិដ្ឋ៉ា** ។

-ទទួលដំណើរទស្សនកិច្ចសិក្សារបស់និស្សិតនៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រសេដ្ឋកិច្ច និងមន្ត្រីរាជការ សិស្ស និស្សិត សាធារណៈជន ចូលអានសៀវភៅ ចំនួ ន៥៣៨នាក់ ។

**៤.ការអភិវឌ្ឍន៍ធនធានមនុស្ស៖**

-បើកវគ្គបណ្តុះបណ្តាលក្នុងប្រទេស ចំនួន០៨វគ្គ ស្តីពីការងារបណ្ណាល័យ និងការគ្រប់គ្រងបណ្ណាល័យ, វគ្គអភិបាលកិច្ចសាធារណៈ និងរដ្ឋបាលសម្រាប់អាស៊ាន, វគ្គ Web Design and Mobile វគ្គ Microsoft Office Word 2010, វគ្គ Microsoft Office Excel 2010, វគ្គ Window Sever 2008& Andriod វគ្គភាសាចិនផ្ទៃក្នុងជំហានទី៣ និងវគ្គបច្ចេកវិទ្យាព័ត៌មានដោយក្រុមយុវជនស្ម័គ្រចិត្តកូរ៉េ ។

-អាហារូបករណ៍ថ្នាក់បរិញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ចំនួន៤៤នាក់ នៅតាមសាកលវិទ្យាល័យក្នុងប្រទេស

**+ *ការបណ្តុះបណ្តាលធនធានមនុស្សក្រៅប្រទេស***

-មន្ត្រីចំនួន០១រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការអភិវឌ្ឍគោលនយោបាយ និងការអនុវត្តនៅប្រទេសវៀតណាម ។

-អាហារូបករណ៍ ថ្នាក់បណ្ឌិត និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ចំនួន០៩នាក់ នៅប្រទេសចិន និងវៀតណាម ។

**៥.ការអភិវឌ្ឍន៍ស្ថាប័ន៖**

-បន្តទំនាក់ទំនងជាមួយអ្នកបច្ចេកទេសចិន និងទីប្រឹក្សាពាណិជ្ជកម្មចិនក្នុងការសាងសង់អគារ ០៣ខ្នង០៣ជាន់ ការបំពាក់ជណ្តើរយន្ត និងការជម្រុញគម្រោងជំនួយសុំបន្ថែម (សាងសង់អគារបន្ថែម ១ខ្នងទៀត, ប្រព័ន្ធលូទឹក, ផ្លូវថ្នល់, ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន, ការសាងសង់សាលប្រជុំ ព្រឹទ្ធសភាថ្មី)។

**៦.សន្តិសុខ ធនធាន មធ្យោបាយ ទីកន្លែង៖**

-អង្គភាពសន្តិសុខផ្ទៃក្នុងព្រឹទ្ធសភា បានចាត់កងកម្លាំងការពារសន្តិសុខ សណ្តាប់ធ្នាប់ ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗ ចំនួន០៩លើក ។

-ថតចម្លងឯកសារ ចំនួន១៦៨សំណើ ចងក្រងឯកសារជាសៀវភៅ ចំនួន១៥០ក្បាល ដោះស្រាយសម្ភារ និងសំណើថវិកា ចំនួន១៥៧សំណើ ព្រមទាំងផ្តល់សេវាដឹកជញ្ជូន ចំនួន១៤១លើក ។

-ប្រគល់ម៉ាស៊ីនហ្វូតូកូបពី តុការិយាល័យ កៅអី ទូដាក់ឯកសារ កុំព្យូទ័រ ចំនួន១៥គ្រឿង និងបិទលេខកូដម៉ាស៊ីនហ្វូតូកូបពី កុំព្យូទ័រ តុការិយាល័យ កៅអី ចំនួន២៤គ្រឿង ។ បញ្ចូលហ្គាស ជួសជុល ម៉ាស៊ីនត្រជាក់ ទូរស័ព្ទ បន្ទប់ទឹក បណ្តាញខ្សែរកាប ប្តូរអំពូល ព្រី កុងតាក់ ចំនួន៦៨គ្រឿង។

-ជួសជុលកុំព្យូទ័រ ត្រួតពិនិត្យ បញ្ចូលកម្មវិធីកំចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធីខ្មែរ Unicode,Office ចុះតាមដាន Internet និង Network សរុបចំនួន ៤៧គ្រឿង និងបាន Upload ព័ត៌មាន និងឯកសារផ្សេងៗ ចំនួន៣៧ប្រធានបទ ។

II.**ទិសដៅការងារខែសីហា ឆ្នាំ២០១៣**

១-ត្រៀមបញ្ចប់សម័យប្រជុំលើកទី៣ នៅថ្ងៃទី២២ សីហា ឆ្នាំ២០១៣។

២-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំជាមួយគណៈប្រតិភូជាតិ អន្តរជាតិ និងអង្គទូតនានា ។

៣-ត្រៀមសម្រួលការជួបសវនាការរវាងគណៈកម្មការ និងក្រសួងស្ថាប័ននានា និងការចុះបេសកកម្មតាមបណ្តាខេត្ត។

៤-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស (ការត្រៀមចូលរួមមហាសន្និបាត APF, IPU ទស្សនកិច្ចសិក្សានៅបារាំង និងស្វីស ការផ្លាស់ប្តូរគណៈប្រតិភូក្នុងឱកាសខួបលើកទី៥៥ ទំនាក់ទំនងការទូតកម្ពុជា-ចិន) ។

៥-ការរៀបចំវេទិកាសាធារណៈរបស់ក្រុមសមាជិកព្រឹទ្ធសភាតាមភូមិភាគ ។

៦-ការត្រៀមរៀបចំបំពាក់ការបើនភ្លើង ជណ្តើរយន្ត ប្រព័ន្ធអគ្គិសនី លូទឹក សួនច្បារនៅក្នុងបរិវេណការដ្ឋាន៣ខ្នង និងក្នុងបរិវេណព្រឹទ្ធសភា ។

៧-ការធ្វើងគម្រោងថវិកា ឆ្នាំ២០១៤របស់ព្រឹទ្ធសភា ក្នុងក្របខ័ណ្ឌបច្ចេកទេសជាមួយក្រសួង

សេដ្ឋកិច្ច ក្រសួងហិរញ្ញវត្ថុ និងបន្តសិក្សាអំពីការកែសម្រួលរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន ព្រមទាំងការងារលទ្ធកម្មសាធារណៈ ត្រីមាសទី៣ ។

៨-បន្តការបណ្តុះបណ្តាល និងការរកអាហារូបករណ៍ក្នុង និងក្រៅប្រទេសដល់មន្ត្រី។

៩-បន្តជម្រុញការដ្ឋានសាងសង់អគារ០៣ខ្នង និងបន្តស្វះស្វែងរកជំនួយ និងកិច្ចសហប្រតិបត្តិការ។

១០-ពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការរវាងវិទ្យាស្ថានសភាកម្ពុជា និងសភាកម្ពុជា ព្រមទាំងបន្តបើកទ្វារទៅខាងក្រៅដើម្បីរកជំនួយ និងការគាំទ្របន្ថែម ។

១១-បន្តពិចារណាអំពីការរៀបចំ និងដាក់ឲ្យអនុវត្តអង្គភាពថវិកា សម្រាប់៤អង្គភាពជាជំហានដំបូង ។

១២-ការគិតគូរដល់ដំណើរការប្រព័ន្ធការងារ មធ្យោបាយ និងធនធានសម្រាប់គ្រប់អង្គភាព ព្រមទាំងជីវភាព សុខុមាលភាព មន្ត្រីរាជការ និងបេឡាសង្គមកិច្ច ។

១៣-សិក្សាអំពីការប្រើប្រាស់ថវិការបស់គ្រប់អង្គភាពចំណុះរចនាសម្ព័ន្ធនយោបាយ ។

១៤-បន្តសិក្សាអំពីនីតិវិធីអនុវត្តបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និងរៀបចំចងក្រងប្រវត្តិព្រឹទ្ធសភា និងប្រវត្តិអគារក្រហម អគារ៤ខ្នង ជាជំនួយរបស់ចិន និងអគារ៦ខ្នង ជាជំនួយរបស់ជប៉ុន។

១៥-ត្រៀមការបោះពុម្ពជំណាច់ឆ្នាំ និងប្រទីប ។

**III.សេចក្តីសន្និដ្ឋាន**

ក្នុងខែកក្កដានេះ ជាខែដែលអ្នកនយោបាយជាប់ជំពាក់ច្រើនទៅនឹងការងារបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ នីតិកាលទី៥ ។ ទន្ទឹមនឹងនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅតែបន្តជម្រុញការបណ្តុះបណ្តាលធនធានមនុស្ស និងបំពេញមុខងាររបស់ខ្លួនយ៉ាងសកម្ម ដោយទទួលបានលទ្ធផលល្អប្រសើរ ។ kh

ភ្នំពេញ,ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៣

**អគ្គលេខាធិការ**

**អ៊ុំ_សារីឬទ្ធ**